**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តកែប**

លេខ ១៤៣ ស.ជ.ណា/ខក

កែប,ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការលទ្ធកម្មគម្រោងឃុំ សង្កាត់ឆ្នាំ២០១៥

សាលាខេត្តកែប មានកិត្តិយស សូមជម្រាបដល់អ្នកទទួលការទាំងអស់ឱ្យបានជ្រាបថា នៅខែ តុលា ឆ្នាំ២០១៤ខាងមុខនេះ សាលាខេត្តកែបនឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៥ ។ អ្នកទទួលការដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ មានសិទ្ធិដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ នៅគ្រប់ឃុំ សង្កាត់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា ០៣ប្រភេទ៖

ប្រភេទទី១៖ អ្នកទទួលការសំណង់ទូទៅ ( ការងារសំណង់អគារ និងការងារបេតុង...។ល។)

ប្រភេទទី២៖ អ្នកទទួលការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រាលក្រួសក្រហម ...។ល។)

ប្រភេទទី៣៖ អ្នកទទួលការងារឯកទេស(អ្នកទទួលការដែលមានឧបករណ៍ និងជំនាញពិសេសសម្រាប់ការងារពិសេស ដូចជា អណ្តូងស្នប់...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស សម្ភារៈ និងបរិក្ខារគ្រប់គ្រាន់ដូចមានបរិយាយនៅក្នុងពាក្យសុំ ចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ និងត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងនឹងប្រភេទនីមួយៗ ដែលបានស្នើសុំយ៉ាងតិចចំនួន ០២ ក្នុងអំឡុងពេល០៥ឆ្នាំចុងក្រោយ ។ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេស ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យស្នើសុំចុះបញ្ជី ព្រមទាំងពិនិត្យគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក ។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងដាក់ជូនឯកឧត្តមអភិបាលខេត្តដើម្បីពិនិត្យ និងសម្រេច។

អាស្រ័យហេតុនេះ បើអ្នកទទួលការណាមួយមានបំណងចុះបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យនៅសាលាខេត្តកែប ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៤ វេលាម៉ោង ១៧,៣០នាទី។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើងវិញដែរ។ ពាក្យសុំចុះបញ្ជីឈ្មោះអ្នកទទួលការអាចរកបាននៅទីចាត់ការផែនការ និងវិនិយោគខេត្តដោយឥតគិតថ្លៃ ឬទាញយកពីគេហទំព័រ គ.ជ.អ.ប (www.ncdd.gov.kh)។

**អភិបាលខេត្ត**

ម៉ែន.សំភ្លា